ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ............... កសក

# សេចក្តីជូនដំណឹង
# ស្តីពី
# ការលើកពេលប្រឡងចូលបម្រើការងារក្នុងក្របខ័ណ្ឌ
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# សម្រាប់ឆ្នាំ២០២៣

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជម្រាបជូនដំណឹងដល់បេក្ខជនជា សិស្ស និស្សិត ដែលបានដាក់ពាក្យស្នើសុំសិទ្ធិប្រឡងប្រជែង និងទទួលបានសលាកប័ត្រឯកត្តជន ដើម្បីចូលរួមប្រឡងប្រជែងក្នុងក្របខ័ណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ឆ្នាំ២០២៣ ឱ្យបានជ្រាបថា ដើម្បីអនុវត្តនូវសេចក្តីណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅព្រឹកថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ក្នុងពិធីសំណេះសំណាលជាមួយកម្មករ និយោជិត តាមរោងចក្រ សហគ្រាស នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងយោងសេចក្តីជូនដំណឹងលេខ៧១១៩ កសក.សជណ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការប្រឡងប្រជែងចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ឆ្នាំ២០២៣ ក្រសួងសូមជម្រាបជូនថា កាលបរិច្ឆេទនៃការប្រឡងប្រជែងដែលបានកំណត់នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣ មណ្ឌលប្រឡងនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ខាងមុខនេះ នឹងត្រូវបានលើកពេលទៅថ្ងៃក្រោយវិញ។

ចំពោះកាលបរិច្ឆេទថ្មី និងព័ត៌មានផ្សេងៗទៀតពាក់ព័ន្ធនឹងការប្រឡងប្រជែងខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងជម្រាបជូនដំណឹងនៅពេលក្រោយ។

អាស្រ័យដូចនេះ សូម បេក្ខជនជាសិស្ស និស្សិត ជ្រាបជាព័ត៌មាន។

ថ្ងៃ ............ ខែ ............ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ............ ខែ ............ ឆ្នាំ២០២៣

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ:(០២៣) ៧២៣ ០០៨ អ៊ីមែល:info@maff.gov.kh
Phone:(023) 723 008 Email:info@maff.gov.kh ,Website: http://www.maff.gov,kh